ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D361/4/1/3

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINA
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 07 / 2017
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent cha
SANN RADA

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៦)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ីយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧

---

សាធារណៈ: គោសលុប

# សេចក្តីសម្រេចលើសំណើរបស់ [redacted] សុំពន្យារការអនុវត្តកាលកំណត់ដីកាសម្រេច D361/4 ដោយរង់ចាំសេចក្តីសម្រេចនៃនីតិវិធីបណ្តឹងឧទ្ធរណ៍

---

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍**

សូ មូស្សេនី
Susana TOMANOVIĆ
Neville SORAB

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARTI



ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់ [redacted] សុំពន្យារការអនុវត្តកាលកំណត់ដីកាសម្រេច D361/4 ដោយរង់ចាំសេចក្ដីសម្រេចនៃនីតិវិធីបណ្ដឹងឧទ្ធរណ៍" ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ("សំណើសុំពន្យារ")[1]។

១. នៅថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៧ សហមេធាវីការពារក្ដី [redacted] ("សហមេធាវី" និង "អ្នកស្នើសុំ") បានដាក់ការជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍[2] នៅចំពោះមុខក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតប្រឆាំងនឹងដីកាសម្រេចដែលបដិសេធសំណើរបស់គាត់សុំមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំ និងផ្ដល់ការពន្យាពេលតិចតួចបន្ថែមសម្រាប់ការដាក់សំណើសុំបំពេញកិច្ចស៊ើបសួររហូតដល់ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ("ដីកាសម្រេចដែលរងការជំទាស់")[3]។ នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហមេធាវីបានដាក់សំណើសុំពន្យារ ហើយនៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់ខ្លួន[4]។

២. ដោយសំអាងលើយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ[5] សហមេធាវីលើកឡើងថា ការអនុវត្តដីកាសម្រេចដែលរងការជំទាស់ ដែលកំណត់កាលបរិច្ឆេទចុងក្រោយក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ (ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧) ដែលផុតកំណត់មុនកាលបរិច្ឆេទចុងក្រោយក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ (ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៧) នឹងធ្វើឱ្យប៉ះពាល់ដល់ខ្លឹមសារនៃកិច្ចដំណើរ

---

[1] ឯកសារ D361/4/1/1 ("សំណើសុំពន្យារ")។

[2] ការជូនដំណឹងរបស់ [redacted] អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4/1។

[3] ដីកាសម្រេចលើសំណើរបស់ [redacted] សុំពេលវេលារៀបចំឱ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ [redacted] សុំពន្យារកាលបរិច្ឆេទចុងក្រោយចំពោះឯកសារលេខ D361/4 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D361/4/1/2 ("ចម្លើយតប")។ *សូមមើលផងដែរ* អ៊ីមែលផ្ញើជូនភាគី ការណែនាំរបស់អង្គបុរេជំនុំជម្រះដល់ភាគីនៅក្នុងសំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៦) ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៧។

[5] សំណើសុំពន្យារ កថាខណ្ឌ ៨-១០។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ការនីតិវិធីលើបណ្តឹងឧទ្ធរណ៍[6]។ សហមេធាវីអះអាងថា បណ្តឹងឧទ្ធរណ៍អាចទទួលបានជោគជ័យលើអង្គសេចក្តីនៃបណ្តឹងនោះ[7] ថា សំណើសុំពន្យារត្រូវបានគាំទ្រដោយមូលហេតុត្រឹមត្រូវ[8] ថា រយៈពេលនៃសំណើសុំពន្យារនឹងសមហេតុផល[9] ហើយថា វាមិនមែនជាវិធីសាស្ត្រពន្យារពេលទេ[10]។

៣. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា សហមេធាវីពុំបានបង្ហាញអំពីមូលហេតុត្រឹមត្រូវទេ ជាពិសេសដោយសារអាចនឹងមានសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀត ប្រសិនបើបណ្តឹងឧទ្ធរណ៍របស់ពួកគេទទួលបានជោគជ័យ ហេតុនេះ ពុំប៉ះពាល់ដល់សិទ្ធិរបស់អ្នកស្នើសុំឡើយ[11]។ គាត់អះអាងបន្ថែមថា បណ្តឹងឧទ្ធរណ៍អាចមិនទទួលបានជោគជ័យលើអង្គសេចក្តីនៃបណ្តឹងនេះ[12]។

៤. អង្គបុរេជំនុំជម្រះរម្លឹកឡើងវិញថា អង្គជំនុំជម្រះអាចប្រើប្រាស់យុត្តាធិការរបស់ខ្លួនដើម្បីពន្យារដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីចៀសវាងករណីថា សិទ្ធិប្តឹងឧទ្ធរណ៍ពុំមានប្រសិទ្ធភាព ឬដើម្បីរក្សាភាពយុត្តិធម៌នៃដំណើរការបណ្តឹងឧទ្ធរណ៍[13]។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះពុំទទួលយកសំណើសុំពន្យារដីកាសម្រេច ដោយផ្អែកលើពាក្យសុំនោះ ឬបណ្តឹងឧទ្ធរណ៍ដែល

[6] សំណើសុំពន្យារ កថាខណ្ឌ ១១-១៣។

[7] សំណើសុំពន្យារ កថាខណ្ឌ ១៩-២០។

[8] សំណើសុំពន្យារ កថាខណ្ឌ ១៤-១៧។

[9] សំណើសុំពន្យារ កថាខណ្ឌ ១៨។

[10] សំណើសុំពន្យារ កថាខណ្ឌ ២១-២២។

[11] ចម្លើយតប កថាខណ្ឌ ២-៥។

[12] ចម្លើយតប កថាខណ្ឌ ៦-៩។

[13] សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី [redacted] សុំពន្យារការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/3 ("សេចក្តីសម្រេចលើសំណើរបស់ [redacted]") កថាខណ្ឌ ១០ *យោងទៅ* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/អជសង/អជតក (២៦) សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E284/2/1/2 កថាខណ្ឌ ១២។ សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ០៣) ដីកាសម្រេចពន្យារការអនុវត្ត "ដីកាសម្រេចលើពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D14/1/2។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

សហមេធាវីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះទេ[14] ហើយនឹងមិនពិចារណាទៅលើអង្គសេចក្ដីទាំងនោះឡើយ។ នៅក្នុងករណីនេះ មានតែការជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍ប៉ុណ្ណោះ ដែលត្រូវបានដាក់នៅចំពោះមុខក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ ហេតុនេះ អង្គបុរេជំនុំជម្រះមិនទទួលបណ្ដឹងឧទ្ធរណ៍យកមកពិនិត្យ និងមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍បាន និងមិនអាចវាយតម្លៃបានទៅលើសំណើសុំព្យួរ ដោយផ្អែកលើសំអាងហេតុនានាដែលបានរៀបរាប់នៅក្នុងបណ្ដឹងឧទ្ធរណ៍នៅពេលអនាគតឡើយ។

៥. លើសពីនេះទៀត ទោះបីអង្គបុរេជំនុំជម្រះទទួលស្គាល់ពីអត្ថិភាពនៃកាលបរិច្ឆេទកំណត់កៀកៗគ្នាទាំងនេះក៏ដោយ តែអង្គជំនុំជម្រះសន្និដ្ឋានថា អ្នកស្នើសុំពុំបានបង្ហាញពីកាលៈទេសៈពិសេសនានាដែលផ្ដល់យុត្តិកម្មដល់ការព្យួរដីកាសម្រេចដែលរងការជំទាស់ មុនពេលដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនឡើយ។ ជាពិសេស ពុំមានការបង្ហាញថា ការអនុវត្តទៅតាមកាលបរិច្ឆេទកំណត់ដែលមាននៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរ នឹងធ្វើឱ្យប៉ះពាល់ដល់គោលបំណងនៃបណ្ដឹងឧទ្ធរណ៍នៅពេលអនាគត ឬបង្កើតជាស្ថានភាពដែលមិនអាចកែប្រែបាន ដូចជា ការអនុវត្តដីកាសម្រេចដែលរងការជំទាស់ ដែលនឹងមានឥទ្ធិពលដោយផ្ទាល់ទៅលើប្រសិទ្ធភាព និងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីបណ្ដឹងឧទ្ធរណ៍នោះឡើយ។ តាមពិតទៅ ប្រសិនបើបណ្ដឹងឧទ្ធរណ៍ទទួលបានជោគជ័យលើអង្គសេចក្ដីនៃបណ្ដឹងនេះ អ្នកស្នើសុំនឹងទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំ និងដាក់សំណើបន្ថែមដែលគាត់យល់ថាជាការចាំបាច់។

៦. អនុលោមតាមសំអាងហេតុខាងលើ សំណើសុំព្យួរនេះត្រូវបានបដិសេធ។

---

[14] *សូមមើលឧទាហរណ៍* សេចក្ដីសម្រេចលើសំណើរបស់ [redacted] កថាខណ្ឌ ១១។ *សូមមើលផងដែរ* តុលាការ STL សំណុំរឿង CH/AC/2011/01 ដីកាសម្រេចទៅលើសំណើបន្ទាន់របស់អយ្យការសុំព្យួរការអនុវត្តដោយរង់ចាំបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៤។ តុលាការ STL សំណុំរឿង STL-11-01/T/AC/AR126.7 ដីកាសម្រេចទៅលើសំណើបន្ទាន់របស់អយ្យការសុំព្យួរការអនុវត្តបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៤ (“អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការដើម្បីចេញដីកាបង្គាប់ស្ដីពីការព្យួរ *ក្រោយពេល*បណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់មួយរយៈពេលខ្លីប៉ុណ្ណោះ ដោយផ្អែកលើសំអាងហេតុដែលមានរៀបរាប់នៅក្នុងបណ្ដឹងឧទ្ធរណ៍ (អ្នកស្នើសុំត្រូវបង្ហាញកាលៈទេសៈពិសេស)។ នេះដោយសារជាធម្មតា អង្គជំនុំជម្រះតុលាការកំពូលមិនអាចអនុវត្តយុត្តាធិការលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន មុនពេលទទួលបណ្ដឹងឧទ្ធរណ៍ជាក់ស្ដែងនោះទេ” [លុបជើងទំព័រ])។



* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ ៖**

- **បដិសេធ** សំណើសុំព្យួរនេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៧**

**ប្រធាន** **ចៅក្រមអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. • C.E.T.C.

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៉ី ថុល** **Kang Jin BAIK** **ហួត វុទ្ធី**